**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ: ....001.../17 របក

គ.ជ.ប.ជ
NATIONAL COMMITTEE FOR COUNTER TRAFFICKING (N.C.C.T)

**សូមគោរពជូន**

**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

ជាទីគោរពដ៏ខ្ពង់ខ្ពស់

**កម្មវត្ថុ៖** សូមគោរពជូន របាយការណ៍កិច្ចប្រជុំលើកទី៤ ស្តីពី ដំណោះស្រាយករណីអន្តរការីនៃការពោះជំនួស និងសូមគោរពស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

**យោង៖**

- សំណើដោះស្រាយបញ្ហាចំពោះមុខ ក្រោយការបង្ក្រាប របស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលទទួលបានចំណារឯកភាពពី**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ**
- ប្រសាសន៍ដឹកនាំរបស់ **សម្តេចក្រឡាហោម ស ខេង** ក្រោយជំនួបជាមួយស្ថានទូតអូស្ត្រាលី ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូនសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ៖

នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានរៀបចំកិច្ចប្រជុំមន្ត្រីជំនាញដែលជាកិច្ចប្រជុំលើកទី៤ ក្រោយពីបានបង្ក្រាបករណីអន្តរការីនៃការពរពោះជំនួស កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។សមាសភាពចូលរួមមានមន្ត្រីជាន់ខ្ពស់ជាជំនាញ ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្រសួងការបរទេស ដើម្បីបន្តការពិភាក្សា ស្តីពីការរៀបចំបែបបបទ និងនីតិវិធីបណ្តោះអាសន្នសម្រាប់ការនាំទារកដែលកើតដោយការខ្ចីពរពោះជំនួស ទៅប្រទេសគោលដៅ ។

ការកំណត់បែបបទ និងនីតិវិធីជាបណ្តោះអាសន្ននេះ គឺជាការចាំបាច់ ដើម្បីដោះស្រាយបញ្ហាប់ករណីដែលត្រូវបានរកឃើញក្នុងអំឡុងពេលនៃការបង្ក្រាប និងដើម្បីទប់ស្កាត់ការរីករាលដាលអំពើពរពោះជំនួស ដែល *ពាក់ព័ន្ធទៅ នឹងការនាំចេញទារកដោយខុសច្បាប់ ដែលអាចជា អំពើរត់ពន្ធ និង ជួញដូរទារកឆ្លងដែន* ។

តាមរបាយការណ៍ពីក្រុមអ្នកស្រាវជ្រាវព័ត៌មានអូស្ត្រាលីឲ្យកាសែត និងវិទ្យុសម្លេងអូស្ត្រាលី បានឲ្យដឹងថា មានទារកមិនតិចជាង ៧០នាក់ទេ ដែលត្រូវបាននាំពីកម្ពុជា ទៅប្រទេសអូស្ត្រាលី រួចហើយ តែតាមរបាយការណ៍ផ្ទាល់មាត់ពីស្ថានទូត ថាមាន ជាង ១០នាក់ និងរបាយការណ៍ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ថា ក្នុងឆ្នាំ២០១៦ មានការនាំតារកចេញទៅក្រៅប្រទេស តាមច្រកទ្វារអន្តរជាតិ ២៦នាក់ គឺចេញទៅចិន ១៤នាក់ ទៅជប៉ុន ៨នាក់ ទៅសហរដ្ឋអាមេរិក ៥នាក់ និងទៅអូស្ត្រាលី ៦នាក់ ។

*មូលហេតុសំខាន់មួយទៀតគឺ ទារកដែលកើតឡើងពីការខ្ចីពរពោះជំនួស នឹងមិនអាចរក្សាទុកជាមួយអ្នកជួលពរពោះបានឡើយ ព្រោះអ្នកទាំងនេះសុទ្ធតែជាគ្រួសារក្រីក្រ និងដឹងថា កូនទាំងនេះមិនមែនជារបស់គេឡើយ ម្ល៉ោះហើយ គាត់នឹងពុំមានចេតនា និងលទ្ធភាពចិញ្ចឹមដល់ធំពេញវ័យឡើយ ។ កូនទាំងនេះអាប្រឈមនឹងគ្រោះថ្នាក់ ឬក្លាយជាបន្ទុករាជរដ្ឋាភិបាល* ។

**កន្លងមក ទារកត្រូវបាននាំចេញតាមឯកសារដែលត្រូវបានស្នើឡើងដោយស្ថានកុងស៊ុល ដើម្បីសុំការអនុញ្ញាតពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ឲ្យចេញទិដ្ឋាការចេញ តែការធ្វើបែបនេះមិនអាចបញ្ជាក់ពីសាវតារបស់ទារក និងការធានាពីអ្នកនាំចេញចំពោះសុវត្ថិភាពកុមារឡើយ។**

ដើម្បីដោះស្រាយបញ្ហានេះ ចាំបាច់ត្រូវពិនិត្យករណីជាក់ស្តែង ពោលគឺត្រូវរៀបចំបែបបទនីតិវិធីសម្រាប់ការនាំចេញដែលមានការធានាទៅលើសុវត្ថិភាពទារក និងមិនមានហានិភ័យដោយអំពើជួញដូរ ឬរត់ពន្ធទារក ដើម្បីគោលដៅទុច្ចរិត ។

កិច្ចប្រជុំបានពិភាក្សាយ៉ាងផុលផុស និងបានឯកភាពគ្នាថា អ្នកស្នើសុំ និងអ្នកពរពោះ ត្រូវមានកាតព្វកិច្ច ដូចខាងក្រោម ៖

តាមការសិក្សាពីនីតិវិធីពាក់ព័ន្ធ នឹងការសុំកូនអន្តរប្រទេស មានលក្ខ័ណ្ឌមួយចំនួនអាចទទួលយកប្រើប្រាស់បាន តែករណីខុសគ្នាត្រង់ថា កូនដែលត្រូវនាំទៅប្រទេសគោលដៅ គឺជាកូនរបស់អ្នកស្នើសុំ ដោយមានការបញ្ជាក់ពីការពិសោធន៍ DNA ។

ដូចនេះ ត្រូវមានលក្ខ័ណ្ឌមួយចំនួនទៀតដែលត្រូវដាក់បញ្ចូលបន្ថែម និងត្រូវការឲ្យមានស្ថាប័ន និងអង្គភាពទទួលខុសត្រូវ គឺ៖

1. ស្ថានទូតប្រទេសសាមី (អូស្រ្តាលី)
2. ក្រសួងការបរទេស
3. ក្រសួងមហាផ្ទៃ
4. អគ្គនាយកដ្ឋានអន្តោប្រវេសន៍
5. ស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ។

ចំពោះបែបបទនៃការនាំទារកចេញ ត្រូវធ្វើឡើងដោយបុរសជាម្ចាស់មេជីវិត ឬ ដែលហៅថាជាឪពុក តាមរយៈការធ្វើការផ្ទៀងផ្ទាត់ DNA ។ ដូចនេះ ៖

១. **<u>អ្នកស្នើសុំ ឬឪពុក</u>** ត្រូវមានសំណុំលិខិត ដែលឯកសារនីមួយៗ មានសុពលភាពយ៉ាងយូរ ០៦ ខែ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ ។ ឯកសារ មានដូចខាងក្រោម៖

- ✓ អ្នកស្នើសុំ ត្រូវមានអាស័យដ្ឋានជាលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលមានចំណងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា និងមានវ័យមិនតិចជាង ៣០ឆ្នាំ (ចំពោះអ្នកមានសហព័ទ្ធដែលត្រូវមានការឯកភាពពីសហព័ទ្ធក្នុងការស្នើសុំកូន) និងមិនតិចជាង ៤០ ឆ្នាំ ចំពោះ អ្នកដែលនៅលីវ ឬពោះម៉ាយ (?)
- ✓ ពាក្យសុំ ដែលមានរូបថត(ក្នុងពីរខែចុងក្រោយ) និងរូបសហព័ទ្ធ (បើមាន) និងក្រយៅដៃ ដែលក្នុងនោះ បញ្ជាក់ពីគោលបំណង ការធានាអះអាងក្នុងការចិញ្ចឹមបីបាច់រក្សាកូន បានល្អរហូតពេញវ័យ
- ✓ លិខិតបញ្ជាក់ DNA ដែលធានាបិតុភាព
- ✓ លិខិតអនុញ្ញាតឲ្យសុំកូនពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ
- ✓ របាយការណ៍ស្ថានភាពគ្រួសារ មានបញ្ជាក់ពីសមាជិកគ្រួសារ ដែលមានការទទួលស្គាល់ពីក្រសួងមានសត្ថកិច្ច ឬអាជ្ញាធរប្រទេសសាមី
- ✓ សេចក្តីចម្លងសំបុត្រ ឬវិញ្ញាប័នប័ត្រកំណើត របស់សាមីខ្លួនអ្នកស្នើសុំ
- ✓ សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះ ឬលិខិតបញ្ជាក់ភាពនៅលីវ ឬលិខិតមរណភាពរបស់សហព័ទ្ធ និងភាពចាំបាច់ដែលត្រូវសុំយកកូនទៅចញ្ចឹមជាកូនរបស់ខ្លួន
- ✓ លិខិតបញ្ជាក់សុខភាពរបស់សាមីខ្លួនអ្នកស្នើសុំ

- ✓ របាយការណ៍ចិត្តវិទ្យា ធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលទទួលស្គាល់ដោយរដ្ឋាភិបាល នៃប្រទេសសាមី របស់សាមីខ្លួនអ្នកស្នើសុំ
- ✓ លិខិតបញ្ជាក់ថាគ្មានទោស (ឬលិខិតថ្កោលទោស) ចេញដោយអាជ្ញាធរនៃប្រទេសកំណើត និង/ឬ ប្រទេសដែលសាមីខ្លួនអ្នកស្នើសុំរស់នៅអចិន្ត្រៃយ៍ បីឆ្នាំចុងក្រោយ
- ✓ សេចក្តីបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សាមីអ្នកស្នើសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច
- ✓ កិច្ចសន្យាគោរពសិទ្ធិជាកូនរបស់សាមីខ្លួន ក្នុងការផ្តល់ការសិក្សា ការថែទាំ ព្រមទាំងសិទ្ធិទទួលមរតកជាកូនបង្កើតរបស់ខ្លួន
- ✓ កិច្ចសន្យារបស់សាមីអ្នកស្នើសុំ ស្តីពីការផ្តល់ព័ត៌មានពីការវិវត្តន៍លូតលាស់កាយសម្បទា ប្រាជ្ញាស្មារតី និងការអភិវឌ្ឍន៍ផ្សេងៗ ក្រោមការទទួលខុសត្រូវរបស់ខ្លួន រហូតដល់វ័យ ១៨ឆ្នាំ ។ ក្រសួងមានសមត្ថកិច្ចនៃប្រទេសសាមី ត្រូវបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ តាមរយៈស្ថានទូតកម្ពុជាប្រចាំប្រទេសសាមី និងក្រសួងការបរទេស ជាទៀងទាត់ ១ឆ្នាំម្តង និងអាចមានរបាយការណ៍ពិសេស បើសាមីខ្លួនមានភាពចាំបាច់ក្នុងការផ្តល់ព័ត៌មាន
- ✓ សេចក្តីចម្លងលិខិតឆ្លងដែន (និងទិដ្ឋាការដែលមានសុពលភាព)របស់សាមីខ្លួនអ្នកស្នើសុំ
- ✓ លិខិតបញ្ជាក់សុពលភាព និងភាពត្រឹមត្រូវនៃឯកសារទាំងអស់ដែលសាមីខ្លួនបានចងក្រងជាសំណើឯកសារ សម្រាប់ការស្នើសុំ ។

២. **<u>សំណុំលិខិតរបស់អ្នកពរពោះ</u>** ដែលត្រូវភ្ជាប់មកជាមួយៈ

- ✓ លិខិតរបស់មន្ទីរពេទ្យបញ្ជាក់ពីការសម្រាលទារក ស្ថានភាពទារក កាលបរិច្ឆេទ កំណើត ភេទ ..
- ✓ ស្ថានភាពគ្រួសាររបស់អ្នកពរពោះ
- ✓ សំបុត្រកំណើតកូន
- ✓ កិច្ចសន្យាជាមួយអ្នកស្នើសុំកូន ក្នុងការជួលពរពោះ
- ✓ សាលក្រមតុលាការផ្ទេរសិទ្ធិអាណាព្យាបាល ពីអ្នកពរពោះជាម្តាយ ទៅអ្នកស្នើសុំ
- ✓ លិខិតស្នើសុំសញ្ជាតិ ទៅស្ថានទូតប្រទេសសាមីរបស់សាមីខ្លួនអ្នកស្នើសុំ
- ✓ លិខិតផ្តល់សញ្ជាតិរបស់ស្ថានទូតប្រទេសសាមី ។

៣. **<u>នីតិវិធី និងស្ថាប័នអនុវត្តៈ</u>**

ក្រុមបច្ចេកទេស បានឯកភាពគ្នាតាមនីតិវិធីដូចខាងក្រោម៖

- ✓ សំណុំលិខិត របស់សាមីអ្នកស្នើសុំ ត្រូវរៀបចំជាស្រេច និងសុំការទទួលស្គាល់ពីស្ថានទូតប្រទេសសាមី ប្រចាំនៅកម្ពុជា ភ្ជាប់ជាមួយលិខិតអះអាងរបស់ស្ថានទូតទៅលើសំណុំឯកសារ បញ្ជូនទៅក្រសួងការបរទេស ។
- ✓ ក្រសួងការបរទេសចេញ សជណ បញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ។
- ✓ សម្ភាសន៍សាមីខ្លួន បញ្ជាក់ជាកំណត់ហេតុអម, ចេញ សជណ និងអនុញ្ញាតឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ទិដ្ឋាការចេញឲ្យសាមីខ្លួននាំទារកចេញតាមផ្លូវច្បាប់ ។

បែបបទ និងនីតិវិធីនេះ នឹងទាមទារឲ្យបំពេញគ្រប់លក្ខ័ណ្ឌ និងប្រគល់សិទ្ធិជូនក្រសួងមហាផ្ទៃក្នុងការសម្រេចថាត្រូវអនុញ្ញាត ឬមិនអនុញ្ញាត ដោយសិក្សាយ៉ាងល្អិតល្អន់ទៅលើលទ្ធភាព និងសមត្ថភាពរបស់អ្នកស្នើសុំ ។ ករណីនេះ ងាចបើកទូលាយចំពោះអ្នកដែមមិនមាន DNA ជាឪពុក តែត្រូវមានលក្ខ័ណ្ឌ ដោយឡែក តាមច្បាប់សុំកូន ។ បែបបទ និងនីតិវិធីនេះនឹងត្រូវសូមគោរពស្នើសុំរៀបចំជា **សជណ ឬអនុក្រឹត្យ** ដើម្បីអាចអនុវត្តបណ្ដោះអាសន្ន ក្នុងតំណាក់កាលដែលមិនទាន់មានច្បាប់ស្តីពី ការខ្ចីឬជួលពរពោះជំនួសនេះនៅឡើយ ។

អាស្រ័យហេតុនេះ សូមសម្តេចមេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍**

ជូ_ម៉ិនអេង

30/12/16